ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៥៥ សហវ.ប្រក

# ប្រកាស

## ស្តីពី

## គោលការណ៍ណែនាំផ្នែកគណនេយ្យ សំរាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹតលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញការងារចាំបាច់ក្នុងការគ្រប់គ្រងវិស័យធនារ៉ាប់រង ។

## សំរេច

ប្រការ ១ : ដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំផ្នែកគណនេយ្យ សំរាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅកម្ពុជា ។

ប្រការ ២ : គ្រប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅកម្ពុជា ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុនៃការិយបរិច្ឆេទនៃកិច្ចប្រត្តិបត្តិការរបស់ខ្លួនប្រចាំឆ្នាំហិរញ្ញវត្ថុនិមួយៗ (ថ្ងៃទី ១ ខែ មករា- ថ្ងៃទី ៣១ ខែ ធ្នូ) តាមគំរូដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសណែនាំនេះ ដែលរួមមាន បទដ្ឋានអប្បបរមា និង ទំរង់របាយការណ៍ប្រចាំឆ្នាំរៀបចំដោយក្រុមហ៊ុនធានារ៉ាប់រងទូទៅសំរាប់អគ្គនាយក និងសវនករ និង ផ្សព្វផ្សាយអោយសាធារណៈជនដឹងពីតារាងតុល្យការចុងគ្រាប្រចាំឆ្នាំនិមួយៗ ។ ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវមានកាតព្វកិច្ចផ្តល់ពត៌មានច្រើនលើសនេះ ដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៣ : គោលការណ៍អនុវត្តន៍លើគណនេយ្យសំរាប់បុព្វលាភរួមមាន៖

ក. ការទទួលស្គាល់ចំណូលបុព្វលាភ នាដំណាច់ឆ្នាំហិរញ្ញវត្ថុ ត្រូវបានកំណត់ដូចតទៅៈ បុព្វលាភនឹងត្រូវជាចំណូលនៅពេលចាប់ផ្តើមទទួលយកហានិភ័យ ។ បុព្វលាភលើប័ណ្ណសន្យារ៉ាប់រង ដែលមានអាយុកាលច្រើនជាង ១២ ខែ ត្រូវផ្តល់ពត៌មានដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ បុព្វលាភត្រូវបានចាត់ជាចំណូលលើប័ណ្ណសន្យារ៉ាប់រងទាំងនោះ ត្រូវស្របតាមលំនាំហានិភ័យ ។

ខ. តំលៃនៃបុព្វលាភមិនទាន់បង់ រួមទាំង សមតុល្យរបស់ភ្នាក់ងារ និង សមតុល្យធានារ៉ាប់រងបន្តមិនត្រូវច្រើនជាងប្រាក់មិនទាន់សងបន្ទាប់ពីដកចេញនូវសំវិធានធនសំរាប់បំណុលដែលពិបាកទារ ឬ បំណុលសង្ស័យបានឡើយ ។ ក្នុងគោលបំណងនេះ បុព្វលាភមួយចំនួនរួមទាំងសមតុល្យរបស់ភ្នាក់ងារធានារ៉ាប់រង និង សមតុល្យរបស់ធានារ៉ាប់រងបន្តរួមទាំងចំនួនទឹកប្រាក់ ត្រូវធ្វើសំណងតែមិនទាន់បានសងលើសពី ០៦ ខែ គិតចាប់ពីថ្ងៃដែលត្រូវបង់នឹងត្រូវចាត់ទុកថា «បំណុលពិបាកទារ និង បំណុលសង្ស័យ» ។ ចំពោះបំណុលដែលលើសពី ០៦ ខែ ត្រូវមានសំវិធានធននៅក្នុងគណនី ។

គ. ទុនបំរុងសំរាប់បុព្វលាភដែលមិនទាន់ជាចំណូល (ឬហានិភ័យមិនទាន់ផុតកំណត់) សំរាប់ការធានារ៉ាប់រងទូទៅ នឹងត្រូវកំណត់ដោយប្រើប្រាស់វិធីសាស្ត្រសមស្រប ក្នុងការកំណត់បុព្វលាភមិនទាន់កត់ជាចំណូល ដែលអាចទទួលយកបាន ។ ទុនបំរុងសំរាប់ហានិភ័យមិនទាន់ផុតកំណត់នឹងកំណត់ដោយផ្អែកលើមូលដ្ឋាននៃបុព្វលាភដុលដកចេញការធានារ៉ាប់រងបន្ត ដែលបានធានានៅក្នុងកំឡុងពេលនោះ ។ សំរាប់គោលបំណងនេះ ការដកចេញនឹងត្រូវធ្វើឡើងពីបុព្វលាភដុលដោយអនុវត្តលើគ្រប់ការធានារ៉ាប់រងបន្ត រួមទាំងការធានារ៉ាប់រងបន្តនៃហានិភ័យពិសេស និងការធានារ៉ាប់រងបន្ត ដែលប្រាក់បញ្ញើជាទុនបំរុងអប្បបរមានៃការធានារ៉ាប់រងបន្តត្រូវបានរក្សាទុក។

ប្រការ ៤ : គោលការណ៍អនុវត្តន៍លើគណនេយ្យសំរាប់ប្រាក់សំណងរួមមាន៖

១. សំវិធានធនសំរាប់ប្រាក់សំណងដែលមិនទាន់សងសំរាប់អាជីវកម្មធានារ៉ាប់រងទូទៅ នឹងកំណត់ឱ្យប្រើវិធីសាស្ត្រប្រាក់សំណងមិនទាន់សងដែលអាចទទួលយកបានមួយ ។ ពាក់ព័ន្ធនឹង

សិវិធានធនសំរាប់កាតព្វកិច្ចធ្វើសំណងជាលក្ខណៈស្តង់ដារ គឺត្រូវប្រើវិធីសាស្ត្រ ផ្អែកលើករណីជាវិធីសាស្ត្រមូលដ្ឋាន ។ ចំណែកទុនបំរុងអាចត្រូវពិនិត្យឡើងវិញ ដោយប្រើវិធីសាស្ត្រផ្សេងទៀតដូចជាវិធីសាស្ត្រតំលៃជាមធ្យម ឬ វិធីសាស្ត្របមន្ត ដើម្បីវាយតំលៃពីភាពគ្រប់គ្រាន់នៃសិវិធានធន ។ វិធីសាស្ត្រគណិតសាស្ត្រនៃការបង្កើតទុនបំរុងសំរាប់ប្រាក់សំណងមិនអាចជំនួសដោយប្រើវិធីសាស្ត្រតាមករណីឡើយ ។

វិធីសាស្ត្រតំលៃមធ្យម ឬ វិធីសាស្ត្របមន្តអាចប្រើបានតែក្នុងកាលៈទេសៈដូចខាងក្រោម៖

ក) សំរាប់ប្រាក់សំណង ដែលមិនមានទិន្នន័យគ្រប់គ្រាន់ ហើយអាចប៉ាន់ស្មានបំណុលបាន

ខ) សំរាប់សិវិធានធននៃប្រាក់សំណង « កើតមានប៉ុន្តែមិនរាយការណ៍ »

គ) ដើម្បីពិនិត្យភាពគ្រប់គ្រាន់នៃសិវិធានធនទូទៅសំរាប់ប្រាក់សំណងមិនទាន់សង

២. ការរាយការណ៍ប្រាក់សំណង នាវេលាបំណាច់ឆ្នាំហិរញ្ញវត្ថុ ត្រូវអនុវត្តដូចតទៅ៖

ក) ប្រាក់សំណងគួរតែត្រូវចុះបញ្ជីនៅក្នុងបញ្ជីប្រាក់សំណង ហើយធ្វើការប៉ាន់ស្មានពីការចំណាយ ជាបន្ទាន់បន្ទាប់ពីបានទទួលដំណឹងជាលើកដំបូង ។

ខ) សិវិធានធនសំរាប់ប្រាក់សំណង ត្រូវតែធ្វើឡើងដោយប្រើពត៌មានដែលមានទាំងអស់ ហើយសិវិធានធនទាំងអស់ត្រូវតែពិនិត្យឡើងវិញ និង ធ្វើការកែតំរូវទៅតាមពត៌មានដែលមាន។ ចំពោះចំនួនបំណុលដែលបានផ្តល់លើប្រាក់សំណង ត្រូវតែគិតទៅលើការប៉ាន់ស្មានចំនួនដែលសំរេចផ្តល់អោយបានត្រឹមត្រូវបំផុត ឬ ទូទាត់ដោយផ្អែកលើរាល់ការពិតដែលមាន និងលើការសន្មតនៃបំណុលដែលទទួលយក ។

គ) សិវិធានធនសំរាប់ប្រាក់សំណង មិនត្រូវកាត់បន្ថយដោយគ្រាន់តែកត្តៈឯកសារ ឬអ្នកទាមទារប្រាក់សំណងមិនបានឆ្លើយតបភ្លាមៗ។ សិវិធានធននេះ ត្រូវតែរក្សាទុករហូតដល់ប្រាក់សំណងត្រូវបានដកជាពិសេស ឬ ផុតពេលវេលា ។

ឃ) សិវិធានធនសំរាប់ប្រាក់សំណង មិនត្រូវលុបចោលទាំងស្រុងដោយគ្រាន់តែក្រុមហ៊ុនធានារ៉ាប់រងធ្វើការបដិសេធសំណងនោះឡើយ។ នៅពេលដែលការទាមទារសំណងមិនមានអ្វីគួរឱ្យសង្ស័យលើសពីទំហំនៃការធានារ៉ាប់រង សិវិធានធនអាចនឹងត្រូវកាត់បន្ថយទៅដល់កំរិតមួយដែលអាចទូទាត់តាមផ្លូវច្បាប់ ដើម្បីការពារនឹងការចោទប្រកាន់ណាមួយក្នុងករណីណាមានការប្តឹងផ្តល់ទៅដល់តុលាការ ។ សិវិធានធននេះអាចលុបចោលបន្ទាប់ពីរយៈពេល ១២ ខែ ប្រសិនបើគ្មានការវិវត្តន៍ណាមួយទេ ។

ង) នៅពេលដែលប្រាក់សំណងត្រូវបានបដិសេធ ដោយមានការបំពានលើកិច្ចសន្យាធានារ៉ាប់រង ឬ លក្ខខណ្ឌនៃការធានាក្រុមហ៊ុនធានារ៉ាប់រង មិនត្រូវដកសវិធានធនសំរាប់ប្រាក់សំណងចេញពីបញ្ជីរបស់ខ្លួន រហូតដល់ផុតកាលកំណត់នៃការធ្វើសំណង ។ ទោះជាយ៉ាងណាក៏ដោយសវិធានធនអាចកាត់បន្ថយនៅត្រឹមចំនួនដែលគិតថាគ្រប់គ្រាន់ទៅតាមកាលៈទេសៈនៃការបំពានកិច្ចសន្យា ដោយមានការយល់ព្រមពីអ្នកគ្រប់គ្រងក្រុមហ៊ុន ។

ច) សវិធានធនលើរាល់ប្រាក់សំណងដែលមិនទាន់សង ត្រូវតែពិនិត្យឡើងវិញយ៉ាងហោចណាស់ក្នុងមួយឆ្នាំម្តង ដោយបុគ្គលិកជំនាញដែលមានបទពិសោធន៍គ្រប់គ្រាន់នៅក្នុងអាជីវកម្ម ។

ឆ) អ្នកគ្រប់គ្រងក្រុមហ៊ុនត្រូវពិនិត្យឡើងវិញជារៀងរាល់ខែ ពីភាពគ្រប់គ្រាន់នៃសវិធានធនលើប្រាក់សំណងដោយផាត់ទាត់នូវចំនួនដែលបានបង់ជាមួយនឹងសវិធានធនដែលមានចំពោះសំណង ។ នៅពេលដែលការពិនិត្យឡើងវិញបែបនេះបង្ហាញថា ទុនបំរុងមាននិន្នាការទៅរកភាពមិនគ្រប់គ្រាន់ត្រូវចាត់វិធានការជាបន្ទាន់ ។

ជ) នៅចុងឆ្នាំ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវតែធ្វើការពិនិត្យឡើងវិញលើភាពគ្រប់គ្រាន់ទាំងអស់នៃសវិធានធនដោយប្រើវិធីសាស្ត្រស្ថិតិដូចជាចំណាយមធ្យមលើប្រាក់សំណង ឬលំនាំនៃការប្រែប្រួលប្រាក់សំណង ។

៣. សវិធានធនដែលសមល្មមសំរាប់ប្រាក់សំណងដែលកើតឡើងតែមិនទាន់រាយការណ៍ (IBNR) ត្រូវកំណត់ ទៅតាមលំនាំប្រាក់សំណងជាក់ស្តែងដែលធ្លាប់មានក្នុងពេលថ្មីៗកន្លងមក ហើយប៉ាន់ស្មានទៅអនាគត ដោយពិចារណាលើកត្តាដូចខាងក្រោម÷

ក) កំណើននៃអាជីវកម្មដែលរួមមាន បុព្វលាភ ទឹកប្រាក់ធានា ចំនួនហានិភ័យ និងសមាសភាគធុរៈកិច្ច

ខ) ករណីកើតមានសំណង រួមមានចំនួន និង បរិមាណទាក់ទងទៅនឹងទំហំអាជីវកម្ម

គ) ការលេចឡើងនូវប្រាក់សំណងសំរាប់ឆ្នាំដែលធានាបន្តបន្ទាប់ ព្រមទាំងនិន្នាការក្នុងការរាយការណ៍ និង លំនាំនៃការដោះស្រាយទូទាត់ ។

ឃ) ផលប៉ះពាល់ នៃអតិផរណាលើចំនួនប្រាក់សំណង និងការប៉ាន់ស្មានទៅអនាគត និង

ង) ប្រៀបធៀបជាមួយនឹងនិន្នាការទីផ្សារតាមតែអាចធ្វើទៅបាន

៤. នៅពេលកំណត់នូវចំណែកនៃក្រុមហ៊ុនធានារ៉ាប់រងបន្ត នូវប្រាក់សំណងដែលមិនទាន់សង ត្រូវមានការប្រុងប្រយ័ត្ន ដោយមិនរាប់បញ្ចូលក្នុងបំណុលដែលត្រូវទារយកពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ក្នុងករណីដែល ÷

ក) ក្រុមហ៊ុនធានារ៉ាប់រងបន្ត មិនអាចសងបំណុលបាន (អសាធនភាព)

ខ) ក្រុមហ៊ុនធានារ៉ាប់រងបន្ត បានបដិសេធចំពោះប្រាក់សំណង ដោយហេតុផលផ្សេងៗ ឬ

គ) ការទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រងបន្ត មានការលំបាកដោយហេតុផលផ្សេងៗ

**ប្រការ ៥:** ស្តង់ដារគណនេយ្យធានារ៉ាប់រង ជាធម្មតាអនុញ្ញាតអោយក្រុមហ៊ុនធានារ៉ាប់រងទទួលយកហានិភ័យពីបរទេសតាមរយៈសន្ធិសញ្ញា ហើយអាចប្រើប្រាស់វិធីសាស្ត្រធានារ៉ាប់រងចំហ ។

នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងអនុម័តប្រើប្រាស់វិធីសាស្ត្រនេះ ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន ។ នៅពេលទទួលបានការយល់ព្រម ហើយត្រូវប្រកាន់ខ្ជាប់នូវគោល-ការណ៍ណែនាំដូចខាងក្រោម÷

ក) នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងសំរេចចិត្តប្រើប្រាស់វិធីសាស្ត្រទទួលធានារ៉ាប់រងចំហ ក្រុមហ៊ុនត្រូវតែប្រើវិធីសាស្ត្រគណនេយ្យនេះនៅឆ្នាំជាបន្តបន្ទាប់ ។ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងមានបំណងប្តូរទៅប្រើវិធីសាស្ត្រគណនេយ្យ តាមឆ្នាំការិយបរិច្ឆេទ ក្រុមហ៊ុនត្រូវតែផ្តល់ហេតុផលសំរាប់ការសំរេចចិត្តផ្លាស់ប្តូរ និង មានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ) ឆ្នាំធានារ៉ាប់រងត្រូវតែទុកចំហសំរាប់រយៈពេលអតិបរមា ៣៦ខែ ដែលនៅចុងរយៈកាលនៃឆ្នាំធានានោះ ត្រូវបិទបញ្ជីដោយមានសមតុល្យឥណពន្ធ និងប៉ាន់ប្រមាណពីបំណុលពុំទាន់សងសំរាប់ឆ្នាំនោះឱ្យបានត្រឹមត្រូវ ហើយផ្ទេរបំណុលនិងមូលនិធិដែលមានតំលៃស្មើទៅឆ្នាំធានាចំហបន្ទាប់ ។

គ) ចំណូលទាំងអស់ ដែលត្រូវទទួលបានពីក្រុមហ៊ុនធានារ៉ាប់រង និងចំណាយទាំងអស់ដែលត្រូវទូទាត់ចំពោះក្រុមហ៊ុនធានារ៉ាប់រង ដែលពាក់ព័ន្ធក្នុងប្រតិបត្តិការធានារ៉ាប់រងបន្តត្រូវបញ្ចូលជាមូលនិធិ ។ ចំណូលផ្សេងទៀត ដូចជាចំណូលវិនិយោគ ឬ ចំណាយផ្សេងទៀតមិនត្រូវកត់ត្រា ឬ បញ្ចូលក្នុងមូលនិធិទេ ។

ឃ) នៅចុងកាលគណនេយ្យម្តងៗនៃរាល់ឆ្នាំធានារ៉ាប់រងចំហនីមួយៗ ត្រូវមានមូលនិធិគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចសំណង ចំពោះហានិភ័យដែលមិនទាន់ផុតរយៈពេលកំណត់ និងកាតព្វកិច្ចចំពោះការទាមទារសំណងដែលពុំទាន់សង (outstanding claim) (រួមមានការទាមទារប្រាក់ IBNR) ។ ប្រសិន បើមូលនិធិនោះត្រូវបានរកឃើញថាមាន

និនភាពត្រូវបំពេញនិនភាពនោះ ឱ្យបានល្អប្រសើរជាបន្ទាន់ ដោយធ្វើការផ្ទេរអោយបានគ្រប់ចំនួនចូលទៅក្នុងមូលនិធិនោះ ។

ង) ប្រសិនបើមូលនិធិក្លាយជាអវិជ្ជមាន ដោយសារការចំណាយទៅលើបុព្វលាភសំរាប់ការការពារអាជីវកម្ម (portfolio) មុនពេលចំណូលបុព្វលាភនៃអាជីវកម្ម (portfolio) ត្រូវទទួលបានមូលនិធិត្រូវរក្សាទុកតុល្យភាពជាវិជ្ជមាន ដោយមិនគិតពីទស្សនៈសុទិដ្ឋិនិយមរបស់ក្រុមហ៊ុន អំពីលទ្ធផលចុងក្រោយដែលត្រូវទទួលបានសំរាប់ឆ្នាំធានារ៉ាប់រងនោះ ។ មូលនិធិនេះត្រូវបង្កើនបន្ថែមទៀតអោយដល់កំរិតគ្រប់គ្រាន់ល្មម ដើម្បីអាចធ្វើសំណងលើគ្រប់បំណុលទាំងអស់ ។

ច) សំណងសំរាប់ហានិភ័យមិនទាន់ផុតកំណត់ ត្រូវវាយតំលៃផ្អែកលើមូលដ្ឋាននៃការសន្មតច្បាស់លាស់ដោយស្របតាមបុព្វលាភ ដែលមាននិងបំណុលមិនមានរយៈពេលកំណត់ ដែលទាក់ទងទៅនឹងបុព្វលាភទាំងនេះ ។ ការតព្វកិច្ចសងបំណុលនេះ មិនត្រូវតិចជាងចំនួន ដែលបានកំណត់ដោយវិធី ១/៨ សំរាប់ប្រភេទអាជីវកម្មមិនមែននាវា សំបកនាវា និង អាកាសចរណ៍ ឬ ២៥ % ចំពោះអាជីវកម្មដឹកទំនិញតាមនាវា ។

ឆ) ប្រាក់សំណងពុំទាន់សង ត្រូវប៉ាន់ប្រមាណចំពោះកិច្ចព្រមព្រៀងនីមួយៗដោយប្រើប្រាស់មធ្យោបាយល្អបំផុតដែលអាចធ្វើបានផ្អែកលើទិន្នន័យដែលមាន ។ ការប៉ាន់ប្រមាណបែបនេះត្រូវបំពេញដោយការវាយតំលៃសមស្របរបស់ IBNR។ ចំពោះគោលបំណងនេះ ក្រុមហ៊ុនធានារ៉ាប់រងត្រូវពិចារណារៀបចំទិន្នន័យឱ្យដាច់ដោយឡែកពីគ្នា សំរាប់ប្រភេទអាជីវកម្មនីមួយៗ ដូចជាអគ្គីភ័យ តួនាវា ការដឹកទំនិញតាមនាវា វិស្វកម្ម សំរាប់សន្ធិសញ្ញាសមាមាត្រ ការធានារ៉ាប់រងបន្ត និង សន្ធិសញ្ញាទទួលសងលើសពីការខាត (Excess of loss) ។ ក្រៅពីនេះ ការសិក្សាពីគំរូរៀបចំការទាមទារប្រាក់សំណងទៅតាមបទពិសោធន៍ផ្ទាល់របស់ក្រុមហ៊ុនស្របតាមគំរូទីផ្សារដែលបានបង្កើតឡើង សំរាប់ការទាមទារប្រាក់សំណង ដោយរៀបចំផ្អែកលើទិន្នន័យដែលមាន ។

**ប្រការ ៦ :** ទ្រព្យសកម្មដែលត្រូវកែតំរូវ ត្រូវកំណត់ដូចខាងក្រោម៖

១. តំលៃទ្រព្យសកម្មដែលជាបន្ទុក ឬ ជាប់សន្យា ឬ ខ្ទីមិនត្រូវរាប់បញ្ចូលទៅក្នុងមូលធនត្រួតពិនិត្យ (Supervisory Capital) ទេ ។ នេះជាការអនុវត្តន៍ទូទៅសំរាប់អ្នកត្រួតពិនិត្យធានារ៉ាប់រង

ដើម្បីកំណត់ ឱ្យបានច្បាស់នូវទ្រព្យសកម្មដែលអាចធានាបាននូវសាធនភាព និង ទុនបំរុង បច្ចេកទេស ។

២. ទ្រព្យសកម្មអរូបិយត្រូវបានដកចេញ លើកលែងតែមានកិច្ចព្រមព្រៀងច្បាស់លាស់ជាមួយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបញ្ចូលទ្រព្យសកម្មអរូបិយមួយផ្នែក ឬ ទាំងស្រុង ។ ទ្រព្យសកម្មអរូបីគ្មានតំលៃពិតប្រាកដក្នុងអសាធនភាពធានារ៉ាប់រង ។

៣. ប្រាក់កម្ចី ឬ ការវិនិយោគ ឬ ប្រាក់បុរេប្រទាន ឬ បំណុលដែលផ្តល់ជូន ឬ ទទួលបាន ពីនាយក និយោជិក សមាគមី ឬ ភាគី ពាក់ព័ន្ធដែលរួមទាំងក្រុមហ៊ុនត្រូវបានដកចេញ ។ អ្នកត្រួតពិនិត្យការធានារ៉ាប់រង មិនលើកទឹកចិត្តអោយមានកម្ចី ឬ ការវិនិយោគបែបនេះឡើយ ។ ទ្រព្យសកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រង ត្រូវតែប្រើប្រាស់ជាផលប្រយោជន៍របស់ក្រុមហ៊ុន និង អ្នកកាន់បណ្ណសន្យារ៉ាប់រង ។

៤. ទ្រព្យសម្បត្តិ (Properties) ត្រូវបានកំណត់តម្លៃត្រឹម ៥០ % នៃមូលធនត្រួតពិនិត្យ បន្ទាប់ពីកែតំរូវ សំរាប់ការសន្យា ឬ បន្ទុក ។

**ប្រការ ៧ :** គោលការណ៍គណនេយ្យសំរាប់ការវិនិយោគ ត្រូវបានកំណត់ដូចខាងក្រោម៖

១. ទ្រព្យវិនិយោគត្រូវកត់ត្រាតាមថ្លៃដើម ឬ តាមតម្លៃដែលបានវាយតម្លៃឡើងវិញ ។ អ្នកវាយតម្លៃមានវិជ្ជាជីវៈឯករាជ្យ នឹងវាយតម្លៃទ្រព្យសកម្មឡើងវិញនៅក្នុងរយៈពេលមួយជាទៀងទាត់ ដែលយ៉ាងហោចណាស់រៀងរាល់ ៣ឆ្នាំ ម្តង ។ ការវាយតម្លៃនៅឆ្នាំដំបូងត្រូវបញ្ចប់អោយបានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ដើម្បីវាយតម្លៃឡើងវិញ សំរាប់ពិនិត្យលើសាធនភាព ។ ចំនួនសាច់ប្រាក់ដែលវាយតម្លៃឡើងវិញ ត្រូវដាក់ស្នើទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីសុំការយល់ព្រមជាមុន មុនពេលស្នើសុំការអនុម័ត ។ នៅពេលដែលចំនួនសាច់ប្រាក់វាយតម្លៃឡើងវិញនោះតិចជាងថ្លៃដើម មូលធនត្រួតពិនិត្យនឹងត្រូវបានធ្វើការកែតំរូវឡើងវិញ ។ ចំនួនសាច់ប្រាក់ដែលផ្ទេរទៅគណនីរបស់ម្ចាស់ភាគហ៊ុន មិនត្រូវប្រើប្រាស់សំរាប់ទូទាត់ភាគលាភដល់ម្ចាស់ភាគហ៊ុនទេ ប៉ុន្តែនឹងត្រូវជាប់កាតព្វកិច្ចជាទ្រព្យសកម្ម ដែលជាទុន បំរុងត្រូវវាយតំលៃឡើងវិញ ។

២. ទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយខ្លួនឯងផ្ទាល់ គឺជាទ្រព្យសម្បត្តិ ដែលត្រូវកាន់កាប់ និង ត្រូវគ្រប់គ្រងមួយផ្នែក ឬ ទាំងស្រុង ដោយក្រុមហ៊ុនធានារ៉ាប់រងសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន (ហើយមិនមែនជាទ្រព្យសម្បត្តិវិនិយោគទេ) ។ ដូចគ្នានេះដែរ ទ្រព្យសម្បត្តិ ដែលជួល ឬ ស្នាក់នៅដោយក្រុមហ៊ុនមួយផ្សេង ឬ ក្រុមហ៊ុននានា ឬ ក្រុមហ៊ុនសមាគមី នៅក្នុងក្រុមតែមួយ ហើយមិនមែនជាទ្រព្យសម្បត្តិវិនិយោគ ត្រូវបានចាត់ទុកជា ទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយខ្លួន

ឯងផ្ទាល់ ។ ទ្រព្យសម្បត្តិនោះ ត្រូវចាត់ទុកដូចជាទ្រព្យសកម្មថេរ ផ្ទុយនឹងទ្រព្យសម្បត្តិ ដែលកាន់កាប់សំរាប់គោលដៅវិនិយោគ ហើយដែលបានកត់ត្រាជាទ្រព្យសម្បត្តិវិនិយោគ ។

ប្រព្រឹត្តិកម្មគណនេយ្យសំរាប់ទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយខ្លួនឯកផ្ទាល់ គឺមានលក្ខណៈដូចគ្នាទៅនឹងទ្រព្យសម្បត្តិសំរាប់វិនិយោគដែរ ។ ដូច្នេះ ទ្រព្យសម្បត្តិដែលគ្រប់គ្រងដោយខ្លួនឯកផ្ទាល់ អាចត្រូវកត់ត្រាតាមថ្លៃដើម ឬ តាមតម្លៃដែលវាយតម្លៃឡើងវិញ ដកចេញនូវរំលស់ លើកលែងនៅពេលចំនួនសាច់ប្រាក់ ដែលបានវាយតំលៃឡើងវិញទាបជាងថ្លៃដើម ទ្រព្យសម្បត្តិនោះនឹងត្រូវកត់ត្រាតាមតម្លៃ ដែលបានវាយតម្លៃឡើងវិញ ។ ប្រសិនបើថ្លៃដើមទាបជាងចំនួនសាច់ប្រាក់ដែលបានវាយតម្លៃឡើងវិញ នោះក្រុមហ៊ុនធានារ៉ាប់រងមានជំរើសកត់ត្រាតាមថ្លៃដើម ឬ តាមចំនួនសាច់ប្រាក់ដែលបានវាយតម្លៃឡើងវិញ ។ នៅពេលកត់ត្រាតាមតម្លៃដែលបានវាយតម្លៃឡើងវិញ ទ្រព្យសម្បត្តិទាំងនេះនឹងត្រូវវាយតម្លៃឡើងវិញក្នុងរយៈពេលកំណត់មួយជាទៀងទាត់ យ៉ាងហោចណាស់រៀងរាល់ ១០ ឆ្នាំ ម្តង ដោយក្រុមហ៊ុនវាយតម្លៃមានវិជ្ជាជីវៈ និង ឯករាជ្យដែល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចទទួលយកបាន ហើយចំនួនសាច់ប្រាក់ដែលត្រូវវាយតម្លៃឡើងវិញ ត្រូវដាក់ស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មុនពេលអនុម័ត ។ ការវាយតម្លៃលើកដំបូងត្រូវបញ្ចប់អោយបានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៥ ដើម្បីវាយតម្លៃកែតំរូវឡើងវិញ សំរាប់ពិនិត្យពិចារណាអំពីសាធនភាព ។ នៅពេលលក្ខខណ្ឌទីផ្សារបង្ហាញថា បន្ទាប់ពីវាយតម្លៃឡើងវិញ រួចទ្រព្យសម្បត្តិមានតំលៃខ្ពស់ជាងតម្លៃទីផ្សារច្រើន នោះចាំបាច់ត្រូវធ្វើការវាយតម្លៃបន្ថែម ឬ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាអ្នកសំរេច ។

ការវាយតម្លៃទ្រព្យវិនិយោគដោយជ្រើសរើស មិនត្រូវបានអនុញ្ញាតិឡើយ ហើយរាល់ការវាយតម្លៃឡើងវិញ ត្រូវធ្វើឡើងទាំងលើទ្រព្យសម្បត្តិដែលកាន់កាប់ផ្ទាល់ខ្លួន លើកលែងតែទ្រព្យសម្បត្តិទើបទិញថ្មីៗ (ឧទាហរណ៍ៈ មិនលើសពីមួយឆ្នាំមុនពេលវាយតម្លៃ) និង ទ្រព្យសម្បត្តិទាំងឡាយណា ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលស្គាល់ថាមានតម្លៃ ប្រហាក់ប្រហែលនឹងតម្លៃទីផ្សារ ។ ចំណែកឯអតិរេកដែលទទួលបានពីការវាយតំលៃឡើងវិញ ត្រូវចាត់ទុកដូចគ្នានឹងអតិរេកពីការវាយតម្លៃឡើងវិញនៃទ្រព្យវិនិយោគ ។

៣. ការកំណត់តំលៃវិនិយោគអាចធ្វើឡើងនៅតំលៃទាប ឬ តំលៃទីផ្សារទៅតាមប្រភេទនៃវិនិយោគនីមួយៗ ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយមានការកាត់បន្ថយជាទៀងទាត់នូវតំលៃនៃការវិនិយោគជាក់ស្តែងត្រូវបង្កើតអោយមានសវិធានធន សំរាប់រាល់ការថយចុះតំលៃវិនិយោគនោះដោយកត់ត្រាតំលៃឱ្យបានសមស្រប ។ ក្នុងន័យនេះ ការវិនិយោគដ៏សំខាន់មួយគឺទទួលរងនូវផលប៉ះពាល់នៃការថយចុះនូវតំលៃជាទៀងទាត់ ពេលដែលតំលៃទីផ្សារនៃការវិនិយោគនោះខ្ពស់បំផុត

ក្នុងរយៈពេល ២៤ខែ ត្រូវថយចុះតំលៃយ៉ាងតិច ២០% ។ ក្នុងករណីនេះ សវិធានធនត្រូវបង្កើត សំរាប់ភាពខុសគ្នារវាងថ្លៃដើមវិនិយោគ និងថ្លៃទីផ្សារក្នុងរយៈពេល ២៤ខែ ។

**ប្រការ ៨ :** បទបញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩ :** ប្រកាសនេះ មានប្រសិទ្ធភាពពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០០៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

- ឯកសារ- កាលប្បវត្តិ